# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

KINGDOM OF CAMBODIA

Nation - Religion - King

ក្រសួងពាណិជ្ជកម្ម

Ministry of Commerce

No. ២១៧ MOC / M 2004

រាជធានីភ្នំពេញ. ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៤

## ប្រកាស

## ស្តីពីលទ្ធផល នៃការដេញថ្លៃកូតាសំរាប់នាំចេញ សំលៀកបំពាក់ទៅកាន់សហរដ្ឋអាមេរិក ក្នុងឆ្នាំ ២០០៤

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើត ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ប្រព្រឹត្តិទៅរបស់ក្រសួងពាណិជ្ជកម្ម ។
- យោងតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញវាយនភ័ណ្ឌ និង ផលិតផលវាយនភ័ណ្ឌធ្វើពីកប្បាស លែន សរសៃ សិប្បនិម្មិតធ្វើពីដៃមនុស្ស សរសៃរុក្ខជាតិគ្មានជាតិកប្បាស និង សរសៃរល្បាសសូត្រ រវាងរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលសហរដ្ឋអាមេរិក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ១៩៩៩ និងការបន្តសុពលភាពនៃកិច្ចព្រមព្រៀងនេះ តាមអនុស្សារណៈនៃការយោគយល់គ្នាទៅវិញទៅមករវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសហរដ្ឋអាមេរិក ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ។
- យោងតាមកិច្ចប្រជុំគណៈរដ្ឋមន្ត្រីនាថ្ងៃទី ២៩ ខែ មករា ឆ្នាំ ១៩៩៩ ។
- យោងប្រកាសក្រសួងពាណិជ្ជកម្មលេខ ២០៧ MOC/ M 2004 ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៤ ស្តីពីការដាក់ឱ្យ ដេញថ្លៃលើកូតាសំលៀកបំពាក់ដែលត្រូវនាំចេញទៅកាន់សហរដ្ឋអាមេរិកក្នុងឆ្នាំ ២០០៤ ។
- យោងការចាំបាច់នៃការងារ ។

Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister's Mobile Phone (855-12) 821888 Facsimile: (855-23) 213288
URL : http://www.moc.gov.kh E-Mail : champrasidh@hotmail.com
Staff's Mobile Phones: (855-12) 933 323 / 881223 Facsimile: (855-23) 426396

## *សំរេច*

**ប្រការ ១ :** ទទួលស្គាល់លទ្ធផលនៃការដេញថ្លៃកូតា តាមប្រភេទនីមួយៗ សំរាប់ធ្វើការនាំចេញទៅកាន់សហរដ្ឋអាមេរិកក្នុងឆ្នាំ ២០០៤ ដែលបានប្រព្រឹត្តិទៅនាថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៤ នៅទីស្តីក្រសួងពាណិជ្ជកម្ម ដូចមានចែងក្នុងឧបសម្ព័ន A ។

**ប្រការ ២ :** នាយកខុទ្ទកាល័យ អគ្គនាយកបច្ចេកទេស ប្រធាននាយកដ្ឋានកាំកុងត្រូល ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ប្រធាននាយកដ្ឋានរដ្ឋបាល រាល់ម្ចាស់រោងចក្រការដេរសំលៀកបំពាក់ និងសមាជិកគណៈកម្មការគ្រប់គ្រងកូតាសំរាប់នាំចេញ ត្រូវទទួលអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**ចំលងជូន**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ខុទ្ទកាល័យឯកឧបនាយករដ្ឋមន្ត្រី **ហោ ណាំហុង**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

"ដើម្បីជ្រាបជាពតិមាន"

- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

Ministry of Commerce # 20 A & B Prean Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister's Mobile Phone (855-12) 821888 Facsimile: (855-23) 213288
URL : http://www.moc.gov.kh E-Mail : champrasidh@hotmail.com
Staff's Mobile Phones: (855-12) 933 323 / 881223 Facsimile: (855-23) 426396